# សន្ទរកថាឯកឧត្តមរដ្ឋមន្ត្រីក្នុងពិធីបើកសន្និសិទ្ធរួម
# រវាង
# ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង
# ក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុន
# នាថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩

- សូមគោរពឯកឧត្តម **Kuroki Masafumi** ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំកម្ពុជា
- សូមគោរពលោក **Suzuki Yasujiro** ប្រធានតំណាង **JICA** កម្ពុជា
- សូមគោរពឯកឧត្តម **Kawauchi Masataka** អគ្គនាយកនៃក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុនព្រមទាំងប្រតិភូជប៉ុនទាំងអស់
- សូមគោរព ឯកឧត្តមរដ្ឋលេខាធិការ អនុលេខាធិការ
- លោក លោកស្រី ជាទីគោរព

តាងនាមអោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ខ្ញុំសូមថ្លែងអរគុណចំពោះឯកឧត្តម **Suruki Yasujuro** និង ឯកឧត្តម **Kuroki Masafumi** ដែលបានថ្លែងសុន្ទរកថាដ៏ក្បោះក្បាយប្រកបដោយអត្ថន័យ និង សូមវាយតំលៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់ឯកឧត្តមទាំងអស់ក្នុងការចូលរួមសន្និសិទ្ធនាពេលនេះ។ ទាំងនេះ គឺជាមោទនៈភាពមួយដល់យើងខ្ញុំទាំងអស់គ្នាដែលកំពុងមានចំណាប់អារម្មណ៏លើបញ្ហាគ្រប់គ្រង និង ដើម្បីចូលរួម អនុវត្តន៍អោយបានល្អលើការអភិវឌ្ឍន៏វិស័យ **ICT** នៅកម្ពុជា។ ដូចដែល ឯកឧត្តមបានមាន ប្រសាសន៍ក្នុងសុន្ទរកថា រួចហើយអំពីអត្ថប្រយោជន៍ និង គោលបំណងដ៏សំខាន់លើការគ្រប់គ្រងវិស័យ **ICT** និងការកសាងហេដ្ឋារចនាសម្ព័ន្ធ គឺជាកត្តាសំខាន់ក្នុងដំណើរការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិទៅអនាគត។ ឈរលើមូលដ្ឋាននោះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាយុទ្ធសាស្ត្រចតុកោណនាអាណិត្តទី ២ ដែលក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍ត្រូវបានកែទំរង់លើវិស័យរបស់ខ្លួន។ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍បានអនុវត្តការកែទំរង់ដោយគោរពតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាលជាមួយ និង អង្គការជាដៃគូរអភិវឌ្ឍន៏មាន **World Bank ADB** និង **ITU** ជាដើម។

ជាក់ស្តែងយើងបានរៀបចំសហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជា ឱ្យទៅជាប្រតិបត្តិករដោយឡែកពី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍នៅខែ មករា ឆ្នាំ២០០៦ ។ ជាបន្តក្រសួងបានខិតខំប្រឹងប្រែងរៀបចំសេចក្តីព្រៀងច្បាប់ជាមួយដៃគូរអភិវឌ្ឍន៍ដើម្បីដាក់ឆ្លងរាជរដ្ឋាភិបាល និង រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាសំរេច។ រហូតមកដល់បច្ចុប្បន្នរាជរដ្ឋាភិបាលបានសំរេចអោយបង្កើតបញ្ញត្តិករទូរគមនាគមន៍តាមរយៈអនុក្រឹត្យដោយឡែកចេញពីសេចក្តីព្រាងច្បាប់សំដៅជំរុញឱ្យបានលឿននូវការគ្រប់គ្រងវិស័យ ទូរគមនាគមន៍នៅកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!**

រាជរដ្ឋាភិបាល បានបង្កលក្ខណៈបើកទីផ្សារ ទូលាយក្នុងការវិនិយោគ លើវិស័យ **ICT** នៅកម្ពុជា គិតមកដល់បច្ចុប្បន្នកម្ពុជាមានក្រុមហ៊ុនបំរើទូរស័ព្ទចល័ត ចំនួន **៩** និងមានក្រុមហ៊ុនជាច្រើនទៀតដែលចូលរួមសាងសង់បណ្តាញកាប្លិ៍អុបទិចឆ្អឹងខ្នងនៅទូទាំងប្រទេស និង ប្រព័ន្ធទូរស័ព្ទអចល័ត ព្រមទាំងប្រព័ន្ធ **IP** ជា ច្រើនទៀតដូចជា **Internet/VoIP** ជាដើមនៅទូទាំងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។

កំណើនដង់ស៊ីតេ នៃការប្រើប្រាស់ទូរស័ព្ទមានសន្ទុះយ៉ាងខ្លាំងក្លាបើប្រៀបធៀបពីឆ្នាំកន្លងទៅគិតមកដល់បច្ចុប្បន្នអ្នកប្រើប្រាស់ទូរស័ព្ទចំនួន ៣៦.៤ %នៃប្រជារាស្ត្រចំនួន ១៤ លាននាក់។ ក្រសួងប្រៃសណីយ៍ បានផ្តល់លទ្ធភាពជាច្រើនដល់ប្រតិបត្តិករដើម្បីជ្រើសរើសយកបច្ចេកវិទ្យាពីពិភពលោកមកបំរើសេវាទូរស័ព្ទ ជូនប្រជារាស្ត្ររួមមាន **GSM 900/1800 MHz CDMA 450/800MHz** និង ប្រព័ន្ធ **3G**។ មិនតែប៉ុណ្ណោះក្រសួងបានបង្កលក្ខណៈងាយស្រួលដល់ប្រតិបត្តិករទាំងអស់ដែលមានបំណងចង់ប្រើប្រព័ន្ធ **Access WiFi / WiMAX** (ចល័ត /អចល័ត) សំរាប់តំរូវការប្រើប្រាស់ **Internet** នៅទូទាំងកម្ពុជា។ ជាមួយគ្នា នោះដែរក្រសួង ប.ទ បានយកចិត្តទុកដាក់ពង្រីកប្រព័ន្ធបណ្តាញអុបទិចឆ្អឹងខ្នងព្រមទាំងប្រព័ន្ធ **Access** នៅទីក្រុង និងបណ្តាខេត្តសំខាន់ៗមួយចំនួនដើម្បីបំពេញសេចក្តីត្រូវការប្រជារាស្ត្រទាន់ពេលដែលក្នុងនោះមានបណ្តាញកាប្លិ៍អុបទិចឆ្អឹងខ្នងចំនួនប្រមាណ**១៥,៨៤៨ Km** នៅគ្រប់ខេត្តក្រុងទាំងអស់។ ទាំងនេះគឺជាការចូលរួមយ៉ាងសកម្មដើម្បីអភិវឌ្ឍន៍ សេដ្ឋកិច្ចក្នុងប្រទេសក៏ដូចជាក្នុងតំបន់ជាមួយ ប្រទេសជាសមាជិក **ASEAN** សំដៅកាត់បន្ថយភាពក្រីក្របង្កើតការងារ និង ដើម្បីឈានទៅធ្វើសមាហរណ កម្មបច្ចេកវិទ្យាទូរគមនាគមន៍ថ្មីមួយ **Next Generation Networking** ក្នុងគោលបំណងអនុវត្តន៍ យុទ្ធសាស្ត្រក្នុងតំបន់លើ

ប្រធានបទ សេដ្ឋកិច្ចបែប **Broadband Economy** ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ក៏មានពាក្យស្លោក មួយថា “ ICT reaching to the rural ” ដើម្បីអភិវឌ្ឍន៍វិស័យនេះឱ្យដល់ជនបទ។

ទោះជាយ៉ាងដូច្នេះក្តីក្រសួងប្រៃសណីយ៍ក៏មានកាតព្វកិច្ចដ៏ធំផងដែរក្នុងការពង្រឹងការគ្រប់គ្រងរៀបចំអោយមានគោលនយោបាយ និង ច្បាប់គ្រប់បែបយ៉ាង ដែលកំពុងតែរៀបចំដូចជាច្បាប់ប្រកួតប្រជែងវិស័យទូរគមនាគមន៍ ច្បាប់គ្រប់គ្រងរលក អាកាសវិទ្យុ ច្បាប់គ្រប់គ្រងសេវាអ៊ីនធើណែត និងច្បាប់ ផ្សេងៗទៀតជាច្រើនទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!**

ក្រសួងប្រៃសនីយ៍ និង ទូរគមនាគមន៏កំពុងខិតខំប្រឹងប្រែងពង្រីកគុណភាពសមត្ថភាពគ្រប់គ្រងលើការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ពន្ធបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៏។ ក្នុងនោះមានការរៀបចំគោលនយោបាយនិយ័តកម្មសំរាប់ប្រតិបត្តិករទាំងអស់ និង ត្រៀមរៀបចំអនុវត្តន៏ច្បាប់ទូរគមនាគមន៏ព្រមទាំង រៀបចំការបង្កើតបញ្ញត្តិករទូរគមនាគមន៏។

ខ្ញុំសង្ឃឹមថាការជួបជុំពិភាក្សាគ្នារវាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ជាមួយគណៈប្រតិភូ ជប៉ុនដែលមានការជួយឧបត្ថម្ភពីក្រសួង **MIC** ថ្ងៃនេះនឹងផ្តល់ជាគន្លឹះដ៏ល្អៗសំរាប់ជាទុនដល់ក្រសួងយើងខ្ញុំយកទៅអនុវត្តន៏ទាន់ពេលវេលា និងតាមតំរូវការនាពេលបច្ចុប្បន្ន និងទៅអនាគត។ អនុវត្តតាមសេចក្តីថ្លែងការ រួមចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩ កន្លងមកគឺជាកិច្ចសហប្រតិបត្តិការណ៍ដ៏ល្អមួយសំរាប់ក្រសួងទាំងពីរ ដើម្បីបន្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏វិស័យ **ICT** អោយបានកាន់តែរីកចំរើន និងមានគុណភាពនៅកម្ពុជា។

ខ្ញុំមានមោទនភាព និង សូមវាយតំលៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងដើម្បីធ្វើអោយក្រសួងយើងខ្ញុំមានលទ្ធភាពពិភាក្សាសិក្សា និង ពង្រីកគុណភាពគ្រប់គ្រង សំរាប់ចូលរួមអភិវឌ្ឍន៏ហេដ្ឋារចនាសម្ពន្ធវិស័យ **ICT** នៅកម្ពុជា។

ដូចនេះ តាងនាមអោយថ្នាក់ដឹកនាំក្រសួងនិងអង្គសន្និសិទ្ធទាំងមូល ខ្ញុំសូមប្រកាសបើកអង្គសន្និសិទ្ធ ជាផ្លូវការចាប់ពីពេលនេះតទៅ។ ***សូមអរគុណ...!***